ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១១៥៧ ព.ណ.អក

ភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យាពេលចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ទាំងឡាយដែលមិនទាន់បានចុះបញ្ជីសារឡើងវិញ មេត្តាជ្រាបថា ក្រសួងពាណិជ្ជកម្មពិនិត្យឃើញថា រហូតមកទល់ពេលនេះមានក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់មួយចំនួនបានធ្វើការចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម តាមការប្រកាសរបស់ក្រសួងលេខ ៣០០ ពណ.ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងពាណិជ្ជកម្មស្តីពីនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដែលបានកំណត់ឲ្យក្រុមហ៊ុនដែលចុះបញ្ជីមុន ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ មកចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម របស់ក្រសួងពាណិជ្ជកម្ម តាមរយៈគេហទំព័រ: www.businessregistration.moc.gov.kh មុនថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៦។ ទន្ទឹមនេះ ក៏មានក្រុមហ៊ុនមួយចំនួនធំផ្សេងទៀត នៅមិនទាន់បានបំពេញកាតព្វកិច្ចនៃការចុះបញ្ជីសារឡើងវិញនៅឡើយទេ។

ដើម្បីផ្តល់លទ្ធភាពជូនក្រុមហ៊ុន ដែលមិនទាន់បានចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម មានពេលវេលាគ្រប់គ្រាន់ក្នុងការចុះបញ្ជីឡើងវិញ ចៀសវាងបាត់បង់សិទ្ធិនិងកាតព្វកិច្ចរបស់ពាណិជ្ជករស្ថិតក្រោមច្បាប់ពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មសម្រេចពន្យាពេលនៃការចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។ ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយណាដែលមិនចុះបញ្ជីសារឡើងវិញក្នុងអំឡុងពេល ឬ ក្រោយការពន្យាពេលនេះ ក្រសួងពាណិជ្ជកម្មនឹងធ្វើលិខិតបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជម្រះកាតព្វកិច្ចពន្ធដារ និង បញ្ជូនទៅតុលាការដើម្បីអនុវត្តតាមនីតិវិធីច្បាប់។

ក្រសួងពាណិជ្ជកម្មសង្ឃឹមយ៉ាងមុតមាំថា ក្នុងអំឡុងនៃការពន្យាពេលនេះ ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងអស់ រួសរាន់ចុះបញ្ជីសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម តាមការកំណត់ជាក់ជាមិនខាន។